# អស់អញ បានសុខ

| | |
|---|---|
| កើតចាស់ឈឺស្លាប់របស់វា | យើងនាំគ្នាថា របស់អញ |
| កើតទុក្ខក្រៀមមុខបាយមិនឆ្ងាញ់ | ព្រោះមិនតាមអញបន្តិចសោះ។ |
| កើតចាស់ឈឺស្លាប់របស់វា | កុំនាំគ្នាសោកស្តាយស្រណោះ |
| ព្រោះសុទ្ធតែរឿងវាទាំងអស់ | គ្មានរឿងអញសោះបន្តិចណា។ |
| បើយើងយល់ថាគ្មានអញទេ | ទ្រូងយើងបានល្ហែស្បើយទុក្ខា |
| គ្មានខ្លួនគ្មានអញគ្មានអត្តា | ជាជុំសង្ខារទេអ្នកកើយ ។ |
| ដកចិត្តឲ្យផុតពីខន្ធប្រាំ | លែងប្រកាន់មាំអ្វីទៀតឡើយ |
| អស់អញនិងរបស់អញហើយ | បានដល់ត្រាណាត្រើយបរមសុខ។ |

**ចាកទុក្ខកើតព្រោះអញ ឆ្នាំ ២០០០**

| | |
|---|---|
| អញរបស់អញ អញទាំងអស់ | តែគ្មានអញសោះ កន្លែងណា |
| ម្តេចមិននាំគ្នា ប្រើបញ្ញា | ពិចារណារកការណ៍ពិតរឿងអញ។ |

**ចាកទុក្ខកើតព្រោះអញ ឆ្នាំ ២០០០**

## ផ្សាយមេត្តា

| | |
|---|---|
| យើងមិត្តរួមកើត ចាស់ឈឺស្លាប់ | ស្ថិតនៅក្រោមច្បាប់សង្ខារ |
| ត្រូវប្រកាន់ជាប់ធម៌មេត្តា | ករុណាអាណិតគិតជួយគ្នា ។ |
| ត្រូវកុំបៀតបៀនកុំធ្វើទុក្ខ | បាបកម្មគ្រប់មុខពៀរវេរា |
| ត្រូវសាងសុខដល់គេរាល់គ្នា | ឲ្យនៅសុខជា សុខ សុខ ចុះ ៕ |

**ចាកកើតស្លាប់ ឆ្នាំ ២០០៣**

| | |
|---|---|
| ឈ្នះលើខ្លួនឯងប្រសើរណាស់ | ជាងឈ្នះលើពួកអ្នកដទៃ |
| ទូន្មានខ្លួនបានវិសេសថ្លៃ | សង្រួមប្រពៃជាប់ជានិច្ច ។ |
| ទេព្តា មារ ព្រហ្ម និង គន្ធព្វ | សញ្ជឹងសញ្ចប់គិតដូចម្តេច |
| យកជ័យជនោះឲ្យសម្រេច | ធ្វើម្តេចក៏មិនអាចឈ្នះបាន ៕ |

**ឈ្នះខ្លួនឯង ប្រសើរជាងឈ្នះអ្វីទាំងអស់**